ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមករា ឆ្នាំ២០១៦

នៅក្នុងខែមករា ឆ្នាំ២០១៦ នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើក

-អនុញ្ញាតឲ្យលោកជំទាវ Alison Louise ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា

-អញ្ជើញបង្សុកូលឧទ្ទិសកុសលជូនដល់យុទ្ធជន យុទ្ធនារី ដែលបានពលីជីវិតក្នុងសម័យតស៊ូរំដោះជាតិ នៅក្នុងចំការចំប៉ី ( ដែលជាអតីតការដ្ឋានដាំកប្បាសក្នុងរបបប៉ុល ពត ) ស្ថិតក្នុងឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។ ក្នុងឱកាសនោះ សម្តេចក៏បានធ្វើការសំណេះសំណាល សាកសួរសុខទុក្ខលោកតា លោកយាយ និងប្រជាពលរដ្ឋប្រមាណជាង១០០នាក់

-អញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ ដែលមានកូនតូចចាប់ពីអាយុ៦ខែ ដល់០២ឆ្នាំ ចំនួន១០០គ្រួសារ នៅភូមិចំនួន០៣ ក្នុងឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ក្នុងឱកាសនោះ សម្តេចបានចែកជូនបងប្អូន ប្រជាពលរដ្ឋក្នុង០១គ្រួសារ បបររុងរឿង០១កេស និងប្រាក់ចំនួនពីរម៉ឺនរៀល

-អញ្ជើញចុះសួរសុខទុក្ខអតីតយុទ្ធជន និងជាអ្នកចូលរួមចលនាតស៊ូរំដោះប្រទេស



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ជាតិចំនួនពីរគ្រួសារ គឺលោកតា **អ៊ួន លាត** មានជន្មាយុ៨៨ឆ្នាំ និងលោកតា **ប៊ូ ពិន** ជន្មាយុ ៧៣ឆ្នាំ បច្ចុប្បន្នជាមន្ត្រីចូលនិវត្តន៍ រស់នៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

-អញ្ជើញប្រារព្ធពិធីបញ្ចុះបឋមសិលាសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ជាជំនួយរបស់រដ្ឋាភិបាលចិន ជូនចំពោះព្រឹទ្ធសភាកម្ពុជា

-អញ្ជើញសាកសួរសុខទុក្ខឯកឧត្តមនាយឧត្តមសេនីយ៍ **ញឹក ហ៊ួន** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទដែលមានជំងឺកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត

-អញ្ជើញនាំយកបច្ច័យ និងទេយ្យវត្ថុទៅវេរប្រគេនសម្តេចព្រះឧត្តមវង្សា **មួង រ៉ា** ព្រះចៅអធិការវត្ត និងព្រះសង្ឃនៅវត្តមុនីប្រសិទ្ធវង្សដែលស្ថិតនៅសង្កាត់ព្រែកព្នៅរាជធានីភ្នំពេញ និងប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធ**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម និងលោកជំទាវ** ព្រមទាំងយុទ្ធជន យុទ្ធនារីដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាជនកម្ពុជាយើង

-អញ្ជើញជាអធិបតីក្នុងពិធីបូជាសព ឯកឧត្តមនាយឧត្តមសេនីយ៍ **ញឹក ហ៊ួន** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទដែលទទួលមរណភាពនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៦ ក្នុងជន្មាយុ៧៣ឆ្នាំ ដោយរោគាពាធ។ ក្នុងឱកាសនោះ សម្តេចបានផ្តល់កិត្តិយសប្រទានភ្លើងដើម្បីបូជាសពនៅបរិវេណទីលានព្រះមេរុ មុខវត្តបុទុមវត្តី

-អញ្ជើញចូលរួមរំលែកទុក្ខដល់ក្រុមគ្រួសារសពប្រជាពលរដ្ឋចំនួន០២គ្រួសារ ដែលកំពុងប្រារព្ធពិធីបូជាសព និងតំកល់សពធ្វើបុណ្យនៅទីឈាបនដ្ឋាន វត្តទួលសុណ្ណារាម ហៅវត្តទួលសង្កែក្នុងសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ ក្នុងឱកាសនោះ សម្តេចក៏បានចូលបច្ច័យឧបត្ថម្ភគ្រួសារសពទាំង០២ផងដែរ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២១៩ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉ែណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើក

-អញ្ជើញចូលរួមបញ្ចុះបឋមសិលាសាងសង់អគារខុទ្ទកាល័យថ្នាក់ដឹកនាំ ព្រឹទ្ធសភាជាជំនួយរបស់រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣៤ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៣លើក

-អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ក្នុងឱកាសដែលក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តម ទៅពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃ នៅភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ និងឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ចំនួន០២លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី៣៦ នៃទិវាជ័យជំនះ ៧មករា ១៩៧៩-២០១៦

-អញ្ជើញដឹកនាំសមាជិកព្រឹទ្ធសភាទៅគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមនាយឧត្តមសេនីយ៍ **ញឹក ហ៊ួន**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១១៩ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៦៨ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក:**

ពិនិត្យនិងសម្រេចបញ្ជូនសេចក្តីព្រាងច្បាប់ចំនួន០៣ ទៅគណៈកម្មការជំនាញ និងទៅក្នុងរបៀបវារៈប្រជុំពេញអង្គព្រឹទ្ធសភា៖

១.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងរបាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨ នីតិកាលទី៣

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៣ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

៣.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ ព្រឹទ្ធសភា សុំដាក់សេចក្តី

ព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី : ការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី

៤.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី២ ព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

៥.កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.សម័យប្រជុំពេញអង្គចំនួន០៣លើក** :

១.ស្តាប់របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨ នីតិកាលទី៣

២.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

៣.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី

៤.ពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ។

**៤. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមករានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងចំនួន០៣

-គណៈកម្មការពិសេស ប្រជុំពិនិត្យអំពីការរៀបចំសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា ឯកសារ និងនីតិវិធីពាក់ព័ន្ធ ។

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន០១ករណី ទទួលលិខិតឆ្លើយតបពីសាលាខេត្តសៀមរាបចំនួន០១ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន១០ករណី

-ក្រុមមិត្តភាព AIPA, IPU, APF, និងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ប្រជុំស្ដីពីការបែងចែកឥណទានឆ្នាំ២០១៦ និងការរៀបចំថវិកាកម្មវិធី

-ក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-ឡាវ ប្រជុំស្ដីពីការផ្សព្វផ្សាយសេចក្ដីសម្រេចចាត់តាំងក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភាកម្ពុជា-ឡាវ លទ្ធផលការងារប្រចាំឆ្នាំ២០១៥ និងលើកទិសដៅការងារឆ្នាំ២០១៦ និងរៀបចំគណៈប្រតិភូធ្វើទស្សនកិច្ចទៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ភូមិភាគទី២ ភូមិភាគទី៤ ភូមិភាគទី៥ ភូមិភាគទី៦ និងភូមិភាគទី៧ ប្រជុំពិភាក្សាលើគម្រោងរៀបចំវេទិកា និងចុះស្រាវជ្រាវប្រមូលព័ត៌មាននៅរាជធានីភ្នំពេញ ខេត្តព្រៃវែង ខេត្តបាត់ដំបង ខេត្តកំពត ខេត្តកែប និងខេត្តព្រះសីហនុ

-សមាជិកគណៈកម្មការរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ APF ប្រជុំត្រៀមរៀបចំកិច្ចប្រជុំបូកសរុប និងត្រួតពិនិត្យការងារត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ APF និងបញ្ហាផ្សេងៗ

-ប្រជុំជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយព្រឹទ្ធសភា ដើម្បីធ្វើរបាយការណ៍ប្រចាំឆ្នាំ២០១៥ និងទិសដៅបន្តឆ្នាំ២០១៦ និងបញ្ហាផ្សេងៗ

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្ដីពី " សារៈសំខាន់នៃគោលនយោបាយគ្រឿងស្រវឹងចំពោះយុវជន "

-ជួបពិភាក្សាការងារជាមួយឯកឧត្តម **MiKi WATANABE** សមាជិកព្រឹទ្ធសភាជប៉ុន និងជាប្រធានក្រុមមិត្តភាព នៃសមាជិកសភាជប៉ុនមេគង្គ

-អនុញ្ញាតឲ្យលោកឧកញ៉ា **ថៃ ទីណា** អគ្គនាយកក្រុមហ៊ុនរោងចក្រម្សៅមី ក្រុមហ៊ុនបាត់ដំបងអាគ្រោអ៊ិនដាស្រ្ទី ចូលធ្វើបទបង្ហាញស្ដីពី : ដំណើរការរបស់រោងចក្រម្សៅមី

-ជួបពិភាក្សាជាមួយតំណាងមជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP) និងអង្គការចលនាដើម្បីសុខភាពកម្ពុជា (CMH) ព្រមទាំងស្ដាប់បទបង្ហាញពីគោលនយោបាយគ្រឿងស្រវឹង

-ជួបពិភាក្សា និងស្ដាប់បទបង្ហាញរបស់អង្គការសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ស្ដីពីលទ្ធផលស្រាវជ្រាវពីតម្រូវការអាទិភាពរបស់យុវជនកម្ពុជា

-ជួបពិភាក្សាការងារជាមួយលោកស្រី **គារ ថាវី** ប្រធានសមាគមក្រុមប្រឹក្សាក្រុង- ឃុំ សង្កាត់ ខេត្តបាត់ដំបង ដើម្បីត្រៀមរៀបចំវេទិការបស់សមាជិកាព្រឹទ្ធសភា នៅភូមិភាគទី៤ ខេត្តបាត់ដំបង

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន១៥៤លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ - សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៣៦លើក ។

**៤.៣. មុខងារព័ត៌មាន**

-អញ្ជើញចុះបេសកកម្មដើម្បីស្វែងយល់អំពីការអនុវត្តគោល នយោបាយវិមជ្ឈការ វិសហមជ្ឈការនៅថ្នាក់មូលដ្ឋានដើម្បីត្រៀមលក្ខណៈក្នុងការរៀបចំវេទិកាថ្នាក់ខេត្ត នាពេលខាងមុខ នៅខេត្តព្រះសីហនុ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ឈិត គឹមយាត** បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៤ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក(APPF) នៅទីក្រុងវ៉ាន់គូវើ ប្រទេសកាណាដា ។

-ឯកឧត្តម **អាំ សំអាត** អញ្ជើញចូលរួមសិក្ខាសាលាសភាថ្នាក់តំបន់ស្តីពី : ការគ្រប់គ្រងគ្រឿងស្រវឹង និងគោលនយោបាយពាក់ព័ន្ធ នៅទីក្រុងវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)